ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣២៧ សណន-កសក

# សេចក្តីណែនាំអន្តរក្រសួង
## ស្តីពី
## បែបបទ នីតិវិធី និងលក្ខខណ្ឌត្រូវគោរពនៃការផ្តល់សេវារដ្ឋបាល ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលរាជធានី ខេត្ត

រាជរដ្ឋាភិបាលបានសម្រេចបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈអនុក្រឹត្យលេខ១៨អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ ដោយប្រមូលផ្តុំការផ្តល់សេវាលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើប្រតិភូកម្មសេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមួយចំនួនទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមាន ការចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម ការចេញលិខិតអនុញ្ញាត និងវិញ្ញាបនបត្ររនាប័យសត្វ និងផលិតផលសត្វ (បសុពេទ្យបាល) សេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ និងការប្រមូលកម្រៃសេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ប្រភេទ ខ" សេវាលើការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម សេវាលើដំណើរការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់អ្នកផ្គត់ផ្គង់ចែកចាយ អ្នកលក់ដុំលក់រាយ។

ដើម្បីធានាការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងសង្គតិភាព ក្រសួងមហាផ្ទៃ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដូចខាងក្រោម ៖

## I.ផ្នែកជលផល

### ១. ការចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម

#### ក. គោលការណ៍នៃការផ្តល់សេវា

រដ្ឋបាលរាជធានី ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងក្នុងការផ្តល់សេវាចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្មដូចខាងក្រោម៖

| ល.រ | បរិយាយ |
|---|---|
| ១. ផ្នែកទឹកសាប | |
| | -ធ្វើវារីវប្បកម្មក្នុងស្រះដែលមានផ្ទៃក្រឡាលើសពី១០ ០០០ម$^{2}$ ដល់ ២០ ០០០ម$^{2}$ |
| | -ធ្វើវារីវប្បកម្មក្នុងបែរដែលមានផ្ទៃក្រឡាលើសពី ៥០ម$^{3}$ ដល់ ២៥០ម$^{3}$ |
| | -ធ្វើវារីវប្បកម្មក្នុងស៊ងដែលមានផ្ទៃក្រឡាលើសពី ៥ ០០០ម$^{3}$ ដល់ ១០ ០០០ម$^{2}$ |



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax: (855) 23-217 320

| | |
|---|---|
| **២. ផ្ទៃកសមុទ្រ** | |
| | -ធ្វើវារីវប្បកម្មស្រែបង្គា ឬស្រះដែលមានផ្ទៃក្រឡាលើសពី១០ ០០០ម² ដល់ ២០ ០០០ម² |
| | -ធ្វើវារីវប្បកម្មវារីរុក្ខជាតិគ្រប់ប្រភេទមានផ្ទៃក្រឡាលើសពី ១០ ០០០ម² ដល់ ២០ ០០០ម² |
| | -ធ្វើវារីវប្បកម្មវារីសត្វគ្រប់ប្រភេទដែលមានផ្ទៃក្រឡាលើសពី ១០ ០០០ម² ដល់ ១៥ ០០០ម² |
| | -ធ្វើវារីវប្បកម្មក្នុងបែរដែលមានផ្ទៃក្រឡាលើសពី៥០ម² ដល់២៥០ម² |
| **៣. ការធ្វើវារីវប្បកម្មត្រីរស់ ត្រីឆ្លោ** | |
| | -ធ្វើវារីវប្បកម្មក្នុងស្រះដែលមានផ្ទៃក្រឡាលើសពី១ ០០០ម² ដល់ ២ ០០០ម² |
| | -ធ្វើវារីវប្បកម្មក្នុងស៊ងដែលមានផ្ទៃក្រឡាលើសពី៥០០ម² ដល់១ ០០០ម² |
| | -ធ្វើវារីវប្បកម្មក្នុងបែរមានផ្ទៃក្រឡាលើសពី១៥០ម² ដល់ ២៥០ម² |
| | -ចិញ្ចឹមលើសពី១០ ០០០ ក្បាល ដល់ ៣៥ ០០០ក្បាល |

ការចេញលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- អ្នកស្នើសុំត្រូវមានសញ្ជាតិខ្មែរ
- មាននិយាមកានៃទីតាំងស្នើសុំច្បាស់លាស់
- ជាដីមានកម្មសិទ្ធិ ឬដីកាន់កាប់ស្របច្បាប់ អាចជាដីផ្ទាល់ខ្លួន ឬដីជួល (ត្រូវថតចម្លងលិខិតផ្ទេរសិទ្ធិ ឬប័ណ្ណកម្មសិទ្ធិ ឬលិខិតកាន់កាប់ ឬលិខិតជួលដី ដែលមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន)
- ចំពោះដីសាធារណៈរបស់រដ្ឋ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរឃុំ/សង្កាត់ (អនុញ្ញាតឱ្យតែអាស្រ័យផលពីការធ្វើវារីវប្បកម្មតែប៉ុណ្ណោះ)
- ជាទីតាំងដែលគ្មានទំនាស់ដីធ្លី ឬទំនាស់ផ្នែកសិទ្ធិអាស្រ័យផល
- មានប្រព័ន្ធការពារមិនឱ្យត្រីរួចចេញពីកសិដ្ឋាន
- ជាប្រភេទពូជដែលអនុញ្ញាតដោយរដ្ឋបាលជលផល
- មិនមែនជាប្រភេទដែលកំពុងរងគ្រោះថ្នាក់
- ជាពូជដែលផលិតដោយស្ថានីយផលិតកូនត្រីពូជ មិនមែនចាប់ពីធម្មជាតិ
- មិនយកកម្រៃសេវាពីប្រជាពលរដ្ឋ លើកលែងតែមានការកំណត់ផ្សេងពីនេះ
- គោរពតាមបទបញ្ជាបច្ចេកទេសវារីវប្បកម្មរបស់រដ្ឋបាលជលផល(មានកិច្ចសន្យា)។

## ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម ៖

- ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម..........ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)..........ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........ចំនួន១ច្បាប់
- កិច្ចសន្យាធ្វើវារីវប្បកម្ម..........ចំនួន១ច្បាប់

- ឯកសារបញ្ជាក់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ឬកិច្ចសន្យាជួល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ...............................................................ចំនួន១ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរឃុំ/សង្កាត់ (**ករណីទីតាំងស្នើសុំជាទ្រព្យសម្បត្តិសាធារណៈ**)...........ចំនួន១ច្បាប់។

**គ. នីតិវិធីនៃការផ្តល់សេវា**

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងវារីវប្បកម្មស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវានោះតាមនីតិវិធីដូចខាងក្រោម ៖
  - ពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីកំណត់ពេលវេលាក្នុងការចុះពិនិត្យទីតាំងផ្ទាល់ និងយកនិយាមកានៃទីតាំងស្នើសុំ
  - ក្នុងករណីចាំបាច់ ត្រូវជួបពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសិក្សាពីប្រវត្តិនៃទីតាំងដែលស្នើសុំ ការប្រើប្រាស់ទឹក និងផលប៉ះពាល់ដែលអាចកើតចេញពីការធ្វើអាជីវកម្មដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
  - ពិនិត្យនូវពូជត្រីដែលស្នើសុំធ្វើវារីវប្បកម្មជាពូជដែលអនុញ្ញាត ឬពូជកំពុងរងគ្រោះ និងជាប្រភេទដែលបង្កាត់បានដោយស្ថានីយផលិតពូជត្រី ឬជាប្រភេទដែលចាប់ពីធម្មជាតិ (ផ្អែកលើលិខិតបទដ្ឋានគតិយុត្ត)
  - ពិនិត្យមើលវិញ្ញាបនបត្របញ្ជាក់ពីសុខភាពកូនត្រី និងប្រភពកូនត្រីពូជ
  - ពិនិត្យមើលពីប្រភពទឹកបង្ហូរចូល និងបង្ហូរចេញពីកសិដ្ឋាន (ប៉ះពាល់ដល់មជ្ឈដ្ឋានជុំវិញឬទេ)
  - ពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធក្នុងគម្រោងកសិដ្ឋានស្នើសុំ ។
- ក្រោយពីបានពិនិត្យបច្ចេកទេសលើទីតាំងវារីវប្បកម្មដែលបានស្នើសុំរួចរាល់ បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "**កំណត់បង្ហាញរឿង**" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំ និងត្រូវរៀបចំ**សេចក្តីព្រាងលិខិតអនុញ្ញាត** រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ។ ក្នុងករណីដែលការស្នើសុំនោះមិនមានលក្ខណៈសមស្របតាមបច្ចេកទេសដែលមិនអាចផ្តល់សេវាជូនបាន បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ**សេចក្តីព្រាងលិខិតឆ្លើយតប** ដោយបញ្ជាក់អំពីមូលហេតុនៃការមិនផ្តល់សេវាជូនបាន រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយវិញ
- បន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីបុគ្គលិកផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និង**សេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតប** ដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

## II.ផ្នែកនីតិកម្មកសិកម្ម

### ១. ដំណើរការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ

**ក. គោលការណ៍នៃការផ្តល់សេវា**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវធ្វើអាជីវកម្មលក់ដុំលក់រាយថ្នាំកសិកម្ម ជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។

ដំណើរការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- អ្នកចូលរួមវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវមានសញ្ជាតិខ្មែរ
- ប្រជាពលរដ្ឋដែលមានបំណងចុះឈ្មោះចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈអាចចុះឈ្មោះនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តណាមួយក៏បានដែលនៅជិតបំផុត
- ដំណើរការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវអនុវត្តស្របតាមកម្មវិធីដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវមានអ្នកចូលរួមយ៉ាងតិចចំនួន៣០នាក់
- វិញ្ញាបនបត្របញ្ជាក់ការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ មានសុពលភាពជាអចិន្ត្រៃយ៍ និងអាចប្រើប្រាស់បានទូទាំងប្រទេស
- វិញ្ញាបនបត្របញ្ជាក់ការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈចេញឱ្យចំពោះតែសិក្ខាកាមដែលបានបំពេញតាមគ្រប់លក្ខខណ្ឌនៃកម្មវិធីបណ្តុះបណ្តាលតែប៉ុណ្ណោះ
- វិញ្ញាបនបត្របញ្ជាក់ការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវចេញ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងចូលរៀនវគ្គបណ្តុះបណ្តាលអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

- ពាក្យស្នើសុំចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលអប់រំសមត្ថភាពវិជ្ជាជីវៈ ........................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)..............................................................................ចំនួន១ច្បាប់
- រូបថត ៤x៦ ..............................................................................ចំនួន២សន្លឹក។

**គ. នីតិវិធីនៃការផ្តល់សេវា**

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ រូបវន្តបុគ្គល ត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- បុគ្គលិកផ្នែកជួរមុខត្រូវកត់ត្រាការស្នើសុំចុះឈ្មោះចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ជាប្រភេទសេវាចុះបញ្ជីជាបណ្តោះអាសន្ន រួចបញ្ជូនសំណុំឯកសារស្នើសុំសេវាទៅប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីចាត់ចែងតាមបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ
- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ ព្រមទាំងបូកសរុបចំនួនសិក្ខាកាមដែលបានស្នើសុំចុះឈ្មោះចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈជូនអភិបាលរាជធានី ខេត្ត មិនឱ្យលើសពីរយៈពេល៣០ថ្ងៃគិតពីថ្ងៃទទួលពាក្យស្នើសុំ។ ការបូកសរុបចំនួនសិក្ខាកាមនេះ ត្រូវធ្វើឡើងឱ្យស្របតាមគោលការណ៍ដែលបានកំណត់នៅក្នុងចំណុច **ក** ខាងលើ។

**គ.១. ក្នុងករណីចំនួនសិក្ខាកាមមានចាប់ពី៣០នាក់ឡើងទៅ៖**

- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ **"កំណត់បង្ហាញរឿង"** ដោយភ្ជាប់មកជាមួយនូវតារាងបញ្ជីឈ្មោះ

សិក្ខាកាមដែលត្រូវចូលរៀនវគ្គរបប់រំសមត្ថភាពវិជ្ជាជីវៈ និងសេចក្តីព្រាងលិខិតស្នើសុំគ្រូឧទ្ទេសទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីដាក់ជូនអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់កាលបរិច្ឆេទ និងសមាសភាពគ្រូឧទ្ទេសសម្រាប់ចូលរួមធ្វើបទបង្ហាញក្នុងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើការឆ្លើយតបមករដ្ឋបាលរាជធានី ខេត្តក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃនៃថ្ងៃធ្វើការ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវជូនដំណឹងទៅសិក្ខាកាមអំពីកាលបរិច្ឆេទ និងទីតាំងសម្រាប់រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ
- ក្នុងការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ រដ្ឋបាលរាជធានី ខេត្តសាមីត្រូវរ៉ាប់រងការចំណាយលើការឧបត្ថម្ភគ្រូឧទ្ទេស និងចំណាយផ្សេងៗទៀតតាមការកំណត់ជាធរមាន
- បន្ទាប់ពីបញ្ចប់ការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដោយភ្ជាប់មកជាមួយនូវតារាងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិក្ខាកាម និងសេចក្តីព្រាងវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ (ដូចមានគំរូជូនភ្ជាប់មកជាមួយ) បញ្ជូនមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងចុះហត្ថលេខា។ ដោយឡែក ចំពោះសិក្ខាកាមដែលមិនបានបញ្ចប់វគ្គអប់រំដោយជោគជ័យ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើ**លិខិតឆ្លើយតប**ទៅសិក្ខាកាមដោយបញ្ជាក់អំពីមូលហេតុដែលមិនអាចផ្តល់វិញ្ញាបនបត្រជូនសិក្ខាកាមនោះ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបញ្ជូនវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈមករដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃនៃថ្ងៃធ្វើការ។

**គ.២. ក្នុងករណីចំនួនសិក្ខាកាមមានតិចជាង៣០នាក់៖**

- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ **"កំណត់បង្ហាញរឿង"** ដោយភ្ជាប់មកជាមួយនូវតារាងបញ្ជីឈ្មោះសិក្ខាកាមដែលត្រូវចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងសេចក្តីព្រាងលិខិតស្នើសុំការសម្របសម្រួលកំណត់ទីតាំងសម្រាប់រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈទៅអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃតាមរយៈប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីដាក់ជូនអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន
- ក្រោយពីទទួលបានលិខិតស្នើសុំពីរដ្ឋបាលរាជធានី ខេត្ត អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃត្រូវកំណត់ទីតាំងសម្រាប់រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើការឆ្លើយតបទៅរដ្ឋបាលរាជធានី ខេត្តដែលមានការពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃនៃថ្ងៃធ្វើការ
- បន្ទាប់ពីបានទទួលលិខិតឆ្លើយតបពីអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានកំណត់ជាទីតាំងសម្រាប់រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ត្រូវរៀបចំលិខិតស្នើសុំគ្រូឧទ្ទេសទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវកំណត់កាលបរិច្ឆេទ និងសមាសភាពគ្រូឧទ្ទេសសម្រាប់ចូលរួមធ្វើបទបង្ហាញក្នុងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ និងធ្វើការឆ្លើយតបមករដ្ឋបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃនៃថ្ងៃធ្វើការ។ រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានកំណត់ជាទីតាំងក្នុង

ការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្តដែលមានសិក្ខាកាមត្រូវចូលរួមវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈអំពីកាលបរិច្ឆេទ និងទីតាំងសម្រាប់រៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ

- ក្នុងការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ រដ្ឋបាលរាជធានី ខេត្ត ដែលមានសិក្ខាកាមចូលរួមក្នុងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈត្រូវចូលរួមជាបដិភាគ ដើម្បីរ៉ាប់រងការចំណាយលើការឧបត្ថម្ភគ្រូឧទ្ទេស និងចំណាយផ្សេងៗទៀតតាមការកំណត់ជាធរមាន
- ក្រោយការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ រដ្ឋបាលរាជធានី ខេត្តដែលត្រូវបានកំណត់ជាទីតាំងក្នុងការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដោយភ្ជាប់មកជាមួយនូវតារាងវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិក្ខាកាម និងសេចក្តីព្រាងវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ (ដូចមានគំរូជូនភ្ជាប់មកជាមួយ) បញ្ជូនមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងចុះហត្ថលេខា ដោយចម្លងជូនរដ្ឋបាលរាជធានី ខេត្តដែលមានការពាក់ព័ន្ធ។ ដោយឡែក ចំពោះសិក្ខាកាមដែលមិនបានបញ្ចប់វគ្គអប់រំដោយជោគជ័យ រដ្ឋបាលរាជធានី ខេត្តសាមីត្រូវធ្វើ**លិខិតឆ្លើយតប**ទៅសិក្ខាកាមដោយបញ្ជាក់អំពីមូលហេតុដែលមិនអាចផ្តល់វិញ្ញាបនបត្រជូនសិក្ខាកាមនោះ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបញ្ជូនវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ មករដ្ឋបាលរាជធានី ខេត្តក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃនៃថ្ងៃធ្វើការ។

## ២. ការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ

### ក. គោលការណ៍នៃការផ្តល់សេវា

រដ្ឋបាលរាជធានី ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងក្នុងការផ្តល់សេវាចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម តាមបរិមាណស្នើសុំប្រតិបត្តិការប្រចាំឆ្នាំដូចខាងក្រោម៖

- ការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ ដែលមានបរិមាណស្នើសុំលើសពី១០០០តោនឡើងទៅ
- ការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ ដែលមានបរិមាណស្នើសុំលើសពី១០តោនឡើងទៅ
- ការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មតាមបរិមាណស្នើសុំធ្វើប្រតិបត្តិការប្រចាំឆ្នាំ ដែលមានបរិមាណលើសពី១០០០តោនឡើងទៅសម្រាប់ជីកសិកម្ម និងលើសពី១០តោនឡើងទៅសម្រាប់ថ្នាំកសិកម្ម។

ការផ្តល់លិខិតអនុញ្ញាត ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- អ្នកស្នើសុំត្រូវមានសញ្ជាតិខ្មែរ
- អ្នកស្នើសុំធ្វើអាជីវកម្មលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អ្នកមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈអាចដាក់ពាក្យស្នើសុំប្រកបអាជីវកម្មបានតែមួយកន្លែងប៉ុណ្ណោះ

- លិខិតអនុញ្ញាតលក់ដុំរបេក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម មានសុពលភាពស្របតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរ ឬការដកហូតស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មនៅមុនកាលបរិច្ឆេទផុតសុពលភាព
- ក្នុងករណីអ្នកកាន់កាប់លិខិតអនុញ្ញាតមានបំណងបន្តធ្វើអាជីវកម្មថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម ក្នុងរយៈពេល៣(បី)ខែ មុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានមិនបានស្នើសុំជាថ្មី អាជីវកម្មនោះត្រូវចាត់ទុកថាបានបិទជាស្វ័យប្រវត្តិ។ ចំពោះការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវអនុវត្តនីតិវិធីដូចការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដំបូង
- មិនអនុញ្ញាតឱ្យផ្ទេរលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មទៅឱ្យអ្នកដទៃឡើយ ទោះបីជាមានការព្រមព្រៀងពីសាមីខ្លួនក៏ដោយ
- លិខិតអនុញ្ញាតដែលផ្តល់ជូនសាមីអ្នកស្នើសុំ ប្រើសម្រាប់តែអាជីវកម្មលក់ដុំលក់រាយតែមួយទីតាំងប៉ុណ្ណោះ
- ក្នុងករណីមានការប្តូរទីតាំងអាជីវកម្មក្នុងរយៈពេលសុពលភាពនៃលិខិតអនុញ្ញាត ត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅទីតាំងថ្មីនោះ ស្របតាមនីតិវិធីជាធរមាន
- អាជីវកម្មលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មអាចធ្វើអាជីវកម្មបានចំពោះតែប្រភេទថ្នាំកសិកម្ម និងជីកសិកម្មដែលបានចុះបញ្ជិកាស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

**ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោមៈ

- ពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម ..........ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្ទិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)..........ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........ចំនួន១ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........ចំនួន១ច្បាប់
- រូបថត ៤x៦..........ចំនួន២សន្លឹក។

**គ. នីតិវិធីនៃការផ្តល់សេវាលើការចេញលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម**

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងអាជីវកម្មនោះ

ស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់មកពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវានោះតាមនីតិវិធីដូចខាងក្រោម៖
    - ពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីកំណត់ពេលវេលាក្នុងការចុះពិនិត្យទីតាំងផ្ទាល់
    - ពិនិត្យផ្ទៀងផ្ទាត់ភាពអនុលោមតាមច្បាប់នៃយថាប្រភេទថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្មដែលបានចុះលេខបញ្ជិកាចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- ក្រោយពីបានពិនិត្យបច្ចេកទេសលើទីតាំងអាជីវកម្មដែលបានស្នើសុំរួចរាល់ បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "**កំណត់បង្ហាញរឿង**" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំ និងត្រូវរៀបចំ**សេចក្តីព្រាងលិខិតអនុញ្ញាត** រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ។ ក្នុងករណីដែលការស្នើសុំនោះមិនមានលក្ខណៈសមស្របតាមបច្ចេកទេសដែលមិនអាចផ្តល់សេវាជូនបាន បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ**សេចក្តីព្រាងលិខិតឆ្លើយតប** ដោយបញ្ជាក់អំពីមូលហេតុនៃការមិនផ្តល់សេវាបាន រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយវិញ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់បច្ចេកទេសពីបុគ្គលិកផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និង**សេចក្តីព្រាងលិខិតអនុញ្ញាត** ឬ**លិខិតឆ្លើយតប**ដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

## III. ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ (ផលិតកម្ម និងបសុព្យាបាល)

### ១. សេវាកម្មត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ និងការប្រមូលកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ចរាចរក្នុងផ្ទៃប្រទេស"

#### ១.១. សេវាត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ "ចរាចរក្នុងផ្ទៃប្រទេស"

##### ១.១.១. សត្វ

**ក. គោលការណ៍នៃការផ្តល់សេវា**

រដ្ឋបាលរាជធានី ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងក្នុងការផ្តល់សេវាចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរសត្វនៅក្នុងផ្ទៃប្រទេសទៅតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដូចខាងក្រោម៖

- សត្វចតុប្បាទស្រុកធំ(ពេញវ័យ)៖ គោ ក្របី សេះ...
- សត្វចតុប្បាទស្រុកធំ(កូន)៖ គោ ក្របី សេះ...
- សត្វចតុប្បាទតូច(ពេញវ័យ)៖ ជ្រូក ពពែ ចៀម...
- សត្វចតុប្បាទតូច(កូន)៖ ជ្រូក ពពែ ចៀម...ចំពោះកូនជ្រូកមានទម្ងន់តិចជាង ៣០គ.ក្រ
- បក្សីស្រុក(ពេញវ័យ)៖ មាន់ ទា មាន់បារាំង ក្ងាន...
- បក្សី(កូន)៖ មាន់ ទា មាន់បារាំង ក្ងាន...ទម្ងន់តិចជាង ១៨៥ក្រាម
- ស៊ុតបក្សីសម្រាប់ភ្ញាស់
- ទឹកកាមសត្វ និងអំប្រ៊ីយ៉ុងសត្វ។

ការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ចេញដោយរដ្ឋបាលរាជធានី ខេត្ត អាចធ្វើ

ចរាចរសត្វ ទូទាំងផ្ទៃប្រទេស និងមានសុពលភាពតាមការកំណត់ជាធរមាន

- ការធ្វើចរាចរសត្វក្នុងផ្ទៃប្រទេសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់កសិដ្ឋានដែលបានចុះបញ្ជី ត្រូវមានគោលការណ៍អនុញ្ញាតចរាចរសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មុននឹងស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វនៅរដ្ឋបាលរាជធានី ខេត្ត
- ការធ្វើចរាចរសត្វក្នុងផ្ទៃប្រទេសសម្រាប់ការធ្វើអាជីវកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វចេញដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មុននឹងស្នើសុំវិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វនៅរដ្ឋបាលរាជធានី ខេត្ត
- ចំពោះការធ្វើចរាចរសត្វក្នុងផ្ទៃប្រទេសជាលក្ខណៈគ្រួសារ ឬដោយអង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ មិនតម្រូវឱ្យមានគោលការណ៍អនុញ្ញាតចរាចរសត្វ និងលិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វចេញពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វឡើយ។

**ខ.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរសត្វនៅក្នុងផ្ទៃប្រទេសត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

**ខ.១. ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់កសិដ្ឋាន**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ....................ចំនួន១ច្បាប់
- គោលការណ៍អនុញ្ញាតចរាចរសត្វចេញដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ....................................................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ.................... .ចំនួន១ច្បាប់។

**ខ.២. ចំពោះការធ្វើអាជីវកម្ម**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ....................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ....................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)....................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វចេញដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ..................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ.................... .ចំនួន១ច្បាប់។

**ខ.៣. ចំពោះការចរាចរជាលក្ខណៈគ្រួសារ ឬដោយអង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ....................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ....................................................................ចំនួន១ច្បាប់

- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ សម្រាប់ការស្នើសុំជាលក្ខណៈគ្រួសារ) ......................................ចំនួន១ច្បាប់
- លិខិតទទួលស្គាល់ការចុះបញ្ជីអង្គការ ឬសមាគមដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ឬលិខិតអនុញ្ញាតឱ្យបង្កើតសហគមន៍តាមការកំណត់ដោយលិខិតបទដ្ឋានជាធរមាន (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) .....................................................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ.................... ចំនួន១ច្បាប់។

### ១.១.២ សាច់ និងផលិតផលសត្វដែលអាចបរិភោគបាន

#### ក. គោលការណ៍នៃការផ្តល់សេវា

រដ្ឋបាលរាជធានី ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងក្នុងការផ្តល់សេវាចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសទៅតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដូចខាងក្រោម៖

- សាច់សត្វ ឬបក្សីទាំងមូល សាច់សត្វ ឬបក្សីពុះជា២ផ្ទាំង សាច់សត្វ ឬបក្សីកាប់ជាដុំ សាច់ជាប់ឆ្អឹង សាច់កាប់ជាប់ឆ្អឹង សាច់សុទ្ធ (គ្មានជាប់ឆ្អឹង) និងផ្នែកបន្ទាប់បន្សំដទៃទៀត ស្រស់ ឬរក្សាទុកក្នុងទឹកត្រជាក់ ឬបង្កក(គ.ក្រ)
- សាច់ងៀត សាច់ក្រក មៀវសាច់ ស្បែកជ្រូកក្រៀម (គ.ក្រ)
- ខ្លាញ់សត្វគ្រប់ប្រភេទ មិនទាន់ចម្រាញ់ នៅស្រស់ បង្កក ប្រឡាក់ ត្រាំទឹកអំបិល រាវ ឬកក(គ.ក្រ)
- ទឹកដោះស្រស់(លីត្រ)
- ស៊ុតស្រស់ ប្រៃ កំណរកូន សម្ងួត ចំអិន និងបង្កក(គ្រាប់)។

ការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ចេញដោយរដ្ឋបាលរាជធានី ខេត្ត អាចធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបានទូទាំងផ្ទៃប្រទេស និងមានសុពលភាពតាមការកំណត់ជាធរមាន
- ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសសម្រាប់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់សត្តឃាតដ្ឋាន មិនតម្រូវឱ្យមានគោលការណ៍អនុញ្ញាត និងលិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វទេ ប៉ុន្តែត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត
- ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសសម្រាប់ការធ្វើអាជីវកម្មត្រូវមានលិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មុននឹងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត
- ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសរបស់ក្រុមហ៊ុនដែលបានការអនុញ្ញាតនាំចូលសាច់សត្វ ឬផលិតផលសត្វពីបរទេសមកផ្គត់ផ្គង់នៅរាជធានី ខេត្ត ត្រូវមានគោលការណ៍អនុញ្ញាតពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្តនៃទីតាំងឃ្លាំងសន្និធិស្ថិតនៅ មុននឹងដឹកទៅរាជធានី ខេត្តផ្សេងទៀត

- ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសជាលក្ខណៈគ្រួសារ អង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ (លក្ខណៈម្ហូបម្ហាល ឬសម្រាប់ពិធីបុណ្យប្រពៃណីផ្សេងៗ) មិនតម្រូវឱ្យមានគោលការណ៍អនុញ្ញាត និងលិខិតអនុញ្ញាតប្រមូលទិញសាច់ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វទេ ប៉ុន្តែត្រូវស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត។

**ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរសាច់ និងផលិតផលសត្វដែលអាចបរិភោគបាននៅក្នុងផ្ទៃប្រទេស ត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

**ខ.១. រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់សត្តឃាតដ្ឋាន**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ......................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)......................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ......................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ..................... ចំនួន១ច្បាប់។

**ខ.២. ចំពោះការធ្វើអាជីវកម្ម**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ......................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)......................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ......................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វ ពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ......................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ..................... .ចំនួន១ច្បាប់។

**ខ.៣. ចំពោះក្រុមហ៊ុនដែលទទួលបានការអនុញ្ញាតនាំចូលសាច់សត្វ ឬផលិតផលសត្វពីបរទេស**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- គោលការណ៍អនុញ្ញាតចេញដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ......................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ ......................... .ចំនួន១ច្បាប់។

**ខ.៤. ចំពោះលក្ខណៈគ្រួសារ អង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ (លក្ខណៈម្តងម្កាល ឬសម្រាប់ពិធីបុណ្យប្រពៃណីផ្សេងៗ)**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ....................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលបានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ....................................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ សម្រាប់ការស្នើសុំជាលក្ខណៈគ្រួសារ) .......................................ចំនួន១ច្បាប់
- លិខិតទទួលស្គាល់ការចុះបញ្ជីអង្គការ ឬសមាគមដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ឬលិខិតអនុញ្ញាតឱ្យបង្កើតសហគមន៍តាមការកំណត់ដោយលិខិតបទដ្ឋានជាធរមាន (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ........................................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ ........................ចំនួន១ច្បាប់។

**១.១.៣. ផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាន**

**ក. គោលការណ៍នៃការផ្តល់សេវា**

រដ្ឋបាលរាជធានី ខេត្ត មានសមត្ថកិច្ចគ្រប់គ្រងក្នុងការផ្តល់សេវាចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបាននៅក្នុងផ្ទៃប្រទេសទៅតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដូចខាងក្រោម៖

- ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត(គ.ក្រ)
- ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វដូចជា ឈាមស្រស់ ម្សៅឈាម ឆ្អឹង ម្សៅឆ្អឹង...(គ.ក្រ)
- ចំណីសត្វ(គ.ក្រ)។

ការចេញវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ចេញដោយរដ្ឋបាលរាជធានី ខេត្ត អាចធ្វើចរាចរផលិតផលសត្វ សម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបានទូទាំងផ្ទៃប្រទេស និងមានសុពលភាពតាមការកំណត់ជាធរមាន
- ការធ្វើចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបាន នៅក្នុងផ្ទៃប្រទេសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់សត្តឃាតដ្ឋាន មិនតម្រូវឱ្យមានគោលការណ៍អនុញ្ញាតចរាចរសត្វ សាច់ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វទេ ប៉ុន្តែត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត
- ការចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗ ដែលមិនអាចបរិភោគបាននៅក្នុងផ្ទៃប្រទេស សម្រាប់ការធ្វើអាជីវកម្ម ត្រូវមានលិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មុននឹងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) នៅរដ្ឋបាលរាជធានី ខេត្ត
- ការធ្វើចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបានរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាម្ចាស់កសិដ្ឋាន ឬក្រុមហ៊ុនផលិតចំណីសត្វ ដែលបានចុះបញ្ជីរួច ត្រូវមានគោលការណ៍

អនុញ្ញាតចរាចរសត្វ សាច់ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មុននឹងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) នៅរដ្ឋបាលរាជធានី ខេត្ត

- ការធ្វើចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបាន នៅក្នុងផ្ទៃប្រទេសរបស់អង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ (លក្ខណៈម្តងម្កាល ឬសម្រាប់ពិធីបុណ្យប្រពៃណីផ្សេងៗ) មិនតម្រូវឱ្យមានគោលការណ៍អនុញ្ញាតចរាចរសត្វ សាច់ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វទេ ប៉ុន្តែត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ដែលចេញដោយរដ្ឋបាលរាជធានី ខេត្ត។

**ខ.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) សម្រាប់ការធ្វើចរាចរផលិតផលសត្វសម្រាប់ប្រើក្នុងផ្នែកផ្សេងៗដែលមិនអាចបរិភោគបាននៅក្នុងផ្ទៃប្រទេស ត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

**ខ.១. រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់សត្តឃាតដ្ឋាន**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........................................................................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូន សត្វ សាច់ ឬផលិតផលសត្វ ........................ចំនួន១ច្បាប់។

**ខ.២. ចំពោះការធ្វើអាជីវកម្ម**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតប្រមូលទិញសត្វ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ..........................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ ........................ចំនួន១ច្បាប់។

**ខ.៣. ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់កសិដ្ឋាន ឬក្រុមហ៊ុនផលិតចំណីសត្វ**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្ដិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ សម្រាប់ការស្នើសុំជាលក្ខណៈគ្រួសារ) ........................................ចំនួន១ច្បាប់
- គោលការណ៍អនុញ្ញាតចរាចរសត្វ សាច់ និងផលិតផលសត្វពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (ថតចម្លង) ..........................................................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូន សត្វ សាច់ ឬផលិតផលសត្វ ........................ .ចំនួន១ច្បាប់។

ខ.៤. ចំពោះអង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ......................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្ដិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)...........................................................................................ចំនួន១ច្បាប់
- លិខិតទទួលស្គាល់ការចុះបញ្ជីអង្គការ ឬសមាគមដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ឬលិខិតអនុញ្ញាតឱ្យបង្កើតសហគមន៍តាមការកំណត់ដោយលិខិតបទដ្ឋានជាធរមាន (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................................................................ចំនួន១ច្បាប់
- កិច្ចសន្យាបច្ចេកទេសសម្រាប់ការដឹកជញ្ជូនសត្វ សាច់ ឬផលិតផលសត្វ ........................ .ចំនួន១ច្បាប់។

### ១.១.៤. នីតិវិធីនៃការផ្ដល់សេវាត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល)

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តសាមី។ ដំណើរការនៃការផ្ដល់សេវា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវបញ្ជូនពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ទៅការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត តាមនីតិវិធីរដ្ឋបាល ដើម្បីពិនិត្យ និងផ្ដល់យោបល់បច្ចេកទេស។ ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាលត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីកំណត់ពេលវេលាក្នុងការចុះទៅពិនិត្យ និងវាយតម្លៃដោយផ្ទាល់លើប្រភេទសេវានីមួយៗតាមកម្មវត្ថុដែលបានស្នើសុំទៅតាមបែបបទ នីតិវិធី និងបច្ចេកទេសដែលមានជាធរមាន
- បន្ទាប់មក ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល ត្រូវរៀបចំ "**កំណត់ហេតុ និងកំណត់បង្ហាញរឿង**" ដោយផ្ដល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំ ព្រមទាំង**សេចក្ដីព្រាងវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល)** ដោយមានចុះហត្ថលេខារបស់ខ្លួន រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយវិញ ក្នុងករណីដែលការស្នើសុំនោះមានលក្ខណៈត្រឹមត្រូវតាមបែបបទ និងបច្ចេកទេស។ ប្រសិនបើ ការស្នើសុំនោះមិនមានលក្ខណៈសមស្របតាមបច្ចេកទេសដែលមិនអាចផ្ដល់សេវាជូនបាន ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល ត្រូវរៀបចំ "**កំណត់ហេតុ និងកំណត់បង្ហាញរឿង**" ព្រមទាំងសេចក្ដី

**ព្រាងលិខិតឆ្លើយតប** ដោយបញ្ជាក់អំពីមូលហេតុនៃការមិនផ្ដល់សេវាជូនបាន រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយវិញ

- បន្ទាប់ពីទទួលបានការផ្ដល់យោបល់បច្ចេកទេសពីប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និង**សេចក្ដីព្រាងវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) ឬលិខិតឆ្លើយតប** ដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

### ១.២. សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ប្រភេទ ខ"

#### ក. គោលការណ៍នៃការផ្ដល់សេវា

ការចេញវិញ្ញាបនបត្រអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "**ប្រភេទ ខ**" ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវពិគ្រោះយោបល់ជាមួយប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល និងលើកសំណើជូនអភិបាលរាជធានី ខេត្ត ដើម្បីដាក់ចេញសេចក្ដីសម្រេចចាត់តាំងភ្នាក់ងារបសុពេទ្យសម្រាប់ប្រចាំការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ប្រភេទ ខ" ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ភ្នាក់ងារបសុពេទ្យប្រចាំការនៅសត្តឃាតដ្ឋាននីមួយៗ មានកាតព្វកិច្ចត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងចេញវិញ្ញាបនបត្របញ្ជាក់អនាម័យសាច់ និងផលិតផលសត្វបានតែនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ស្របតាមសេចក្ដីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្តសាមីប៉ុណ្ណោះ
- ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចប្រចាំការនៅសត្តឃាតដ្ឋាន ត្រូវប្រមូលកម្រៃសេវានៅតាមសត្តឃាតដ្ឋានផ្ទាល់តែម្ដង ដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលរាជធានី ខេត្ត ជំនួសឱ្យបុគ្គលិកទទួលបន្ទុកការងារបេឡារបស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។ ក្រោយទទួលកម្រៃសេវាពីប្រជាពលរដ្ឋ ភ្នាក់ងារបសុពេទ្យត្រូវបង់កម្រៃសេវាទាំងនោះមកអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត តាមបែបបទ និងនីតិវិធីជាធរមាន
- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មពិឃាតសត្វគ្រប់ប្រភេទ ត្រូវអនុវត្តនៅក្នុងសត្តឃាតដ្ឋាន
- អង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ យកសត្វរស់ទៅពិឃាតនៅកន្លែងពិធីបុណ្យផ្សេងៗក្នុងលក្ខណៈម្ដងម្កាល ត្រូវមានវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល)
- អង្គការ សមាគម ឬសហគមន៍ដែលមិនរកស្វែងប្រាក់ចំណេញយកសត្វទៅពិឃាតដើម្បីយកសាច់ និងផលិតផលសត្វសម្រាប់ពិធីបុណ្យផ្សេងៗក្នុងលក្ខណៈម្ដងម្កាលត្រូវពិឃាតសត្វនៅក្នុងសត្តឃាតដ្ឋាន ប៉ុន្តែមិនតម្រូវឱ្យមានលិខិតធ្វើអាជីវកម្មពិឃាតសត្វទេ។

#### ខ. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "**ប្រភេទ ខ**" ត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

**ខ.១. រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើអាជីវកម្មពិឃាតសត្វ**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ប្រភេទ ខ" ..........................................................................................................................ចំនួន១ច្បាប់

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្ដិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........................................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) (ថតចម្លង) ........................ចំនួន១ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ សម្រាប់អ្នកពិឃាតសត្វ (ថតចម្លង)......................ចំនួន១ច្បាប់។

**ខ.២. ចំពោះអង្គការ សមាគម ឬសហគមន៍ដែលមិនស្វែងរកប្រាក់ចំណេញ**

- ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "ប្រភេទ ខ" ..........................................................................................ចំនួន១ច្បាប់
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្ដិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) ..........................................................................................ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ)..........................................................................................ចំនួន១ច្បាប់
- លិខិតទទួលស្គាល់ការចុះបញ្ជីអង្គការ ឬសមាគមដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ឬលិខិតអនុញ្ញាតឱ្យបង្កើតសហគមន៍តាមការកំណត់ដោយលិខិតបទដ្ឋានជាធរមាន (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..........................................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល) (ថតចម្លង) ........................ចំនួន១ច្បាប់។

**គ.នីតិវិធីនៃការផ្តល់សេវា**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងដាក់ពាក្យស្នើសុំវិញ្ញាបនបត្រត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅសត្តឃាតដ្ឋាន "**ប្រភេទ ខ**" ត្រូវដាក់ពាក្យស្នើសុំដោយផ្ទាល់ជាមួយភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចដែលប្រចាំការនៅសត្តឃាតដ្ឋាន។

ដំណើរការនៃនីតិវិធីក្នុងការផ្តល់សេវាត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ នៅសត្តឃាតដ្ឋានភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

**គ.១. ការត្រួតពិនិត្យសត្វរស់មុនពេលពិឃាត**

- ត្រូវត្រួតពិនិត្យវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុព្យាបាល)
- ត្រូវពិនិត្យការរក្សាទុកសត្វនៅកន្លែងបង្ខាំងសត្វ ក្នុងសត្តឃាតដ្ឋានរយៈពេលពី១២ (ដប់ពីរ) ទៅ២៤ (ម្ភៃបួន) ម៉ោង មុនពេលពិឃាត
- ត្រូវពិនិត្យសុខភាពសត្វ ពិនិត្យអាការៈខាងក្រៅសត្វដូចជា ពិនិត្យស្បែក រោម វាស់កម្តៅ ដំហរ អាកប្បកិរិយាសង្វាក់ដង្ហើម ច្រមុះ ភ្នែក ភ្នាសសើម ប្រដាប់រំលាយអាហារ ប្រដាប់បន្តពូជ។ល។ ក្នុងករណីសង្ស័យត្រូវបញ្ជូនវត្ថុវិភាគទៅមន្ទីរពិសោធន៍ភ្លាម ដើម្បីធ្វើរោគវិនិច្ឆ័យ
- ត្រូវពិនិត្យការរក្សាទុកឱ្យនៅដាច់ដោយឡែកពីសត្វដទៃចំពោះសត្វដែលសង្ស័យមានជំងឺ ដោយរង់ចាំលទ្ធផលវិភាគ

- ត្រូវហាមឃាត់ការពិឃាតសត្វដែលសង្ស័យមានជំងឺ និងសត្វឈឺ។ ចំពោះសត្វដែលនៅសង្ស័យថាឈឺ សត្វឈឺ និងសត្វស្លាប់ ត្រូវអនុវត្តវិធានបសុពេទ្យតាមការចាំបាច់។

គ.២. ការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ក្រោយពេលពិឃាត

- ត្រូវធ្វើការពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ក្រោយពេលពិឃាត តាមលក្ខណៈប្រព័ន្ធដើម្បីធានាថា សាច់ និងផលិតផលសត្វទាំងនោះមានអនាម័យ និងមានសុវត្ថិភាពសម្រាប់យកទៅបរិភោគ
- ត្រូវធ្វើការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ភ្លាមក្រោយពេលពិឃាត
- ត្រូវបិទស្លាកលើកញ្ចប់សាច់ ឬផលិតផលបក្សី និងត្រូវបង់លេខសម្គាល់ ក្បាល សរីរាង្គ គ្រឿងក្នុង ផ្ទាំងសាច់ និងផ្នែកផ្សេងៗទៀតនៃផ្ទាំងសាច់ ដែលត្រូវធ្វើការត្រួតពិនិត្យអនាម័យ ជៀសវាងការច្រឡំ
- ត្រូវធ្វើការពិនិត្យក្រពេញទឹករងៃ និងគីសនៅលើសាច់ថ្គាល់ អណ្ដាតរបស់គោ ក្របី ជ្រូក និងសត្វចិញ្ចឹមដទៃទៀត
- ត្រូវដាក់នៅដោយឡែកដើម្បីធ្វើការពិនិត្យលម្អិតបន្ថែមទៀតនូវកញ្ចប់សាច់ និងផលិតផលសត្វ ផ្ទាំងសាច់ ឬផ្នែកណាមួយនៃសរីរាង្គ គ្រឿងក្នុង ដែលសង្ស័យថាមិនអាចបរិភោគបាន
- ហាមចៀរ កាត់ចេញ ឬកែច្នៃបំបាត់ស្លាកស្នាម ភស្តុតាងនៃជំងឺ ដែលមាននៅលើផ្ទាំងសាច់ សរីរាង្គ គ្រឿងក្នុង ឬភ្នាសសេរ៉ូម នៅមុនពេលត្រួតពិនិត្យអនាម័យ
- ហាមយកឈាម ផ្នែកណាមួយនៃផ្ទាំងសាច់ សរីរាង្គ គ្រឿងក្នុង ចេញពីកន្លែងពិឃាតដោយពុំបានឆ្លងកាត់ការត្រួតពិនិត្យ។

លទ្ធផលនៃការត្រួតពិនិត្យ និងការសម្រេចចុងក្រោយ លើការអនុញ្ញាតឱ្យយកទៅបរិភោគបាន ឬយកទៅកែច្នៃ គឺជាភារកិច្ចទទួលខុសត្រូវរបស់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច។

ក្រោយពិនិត្យឃើញថាសាច់ និងផលិតផលសត្វ មានអនាម័យ មានគុណភាព និងមានសុវត្ថិភាព ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រូវបោះត្រា ឬអូសត្រាលើផ្ទាំងសាច់ ឬបិទស្លាកសម្គាល់បសុពេទ្យលើកញ្ចប់សាច់ ផលិតផលសត្វ និងចេញវិញ្ញាបនបត្រអនាម័យសាច់ សត្វ និងផលិតផលសត្វ។

ក្នុងករណីមានការណែនាំបន្ថែម មន្ត្រី/ភ្នាក់ងារបសុពេទ្យដែលប្រចាំនៅតាមសត្តឃាតដ្ឋាន "ប្រភេទខ" ត្រូវអនុវត្តតាមការណែនាំនោះ បន្ថែមពីលើការត្រួតពិនិត្យបច្ចេកទេសដែលបានកំណត់នៅក្នុងចំនុច **គ.១** និង **គ.២** ខាងលើ។

## IV. ទម្រង់ពាក្យស្នើសុំ បែបបទ និងលក្ខខណ្ឌភ្ជាប់

រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមទម្រង់ពាក្យស្នើសុំ បែបបទ និងលក្ខខណ្ឌភ្ជាប់ផ្សេងៗសម្រាប់ការផ្ដល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

## V. តម្លៃសេវា រយៈពេល និងសុពលភាពនៃសេវា

កម្រៃសេវា រយៈពេល និងសុពលភាពនៃសេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខាងលើត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានជាធរមាន។

## VI. របាយការណ៍

រដ្ឋបាលរាជធានី ខេត្ត ដោយមានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តជាសេនាធិការ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំនព្វមាស និងប្រចាំឆ្នាំលើការផ្ដល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងកសិកម្ម រុក្ខាប្រហាញ់ និងនេសាទ ដោយចម្លងជូនក្រសួងមហាផ្ទៃ។

ទទួលបានសេចក្តីណែនាំអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តសេចក្តីណែនាំអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំធ្វើវារីវប្បកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................អាយុ........ឆ្នាំ ជនជាតិ................សញ្ជាតិ...................
អត្តសញ្ញាណប័ណ្ណលេខ.....................................មុខរបរ.....................................................................
ទីលំនៅបច្ចុប្បន្នផ្ទះលេខ..................ផ្លូវ.....................ភូមិ.........................ឃុំ/សង្កាត់...................................
ក្រុង/ស្រុក/ខណ្ឌ.......................រាជធានី/ខេត្ត.................................ទូរស័ព្ទលេខ......................................។

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត..............**

**កម្មវត្ថុ** ៖ សំណើសុំធ្វើវារីវប្បកម្ម.................................................................................................។

**១-ធ្វើវារីវប្បកម្មនៅក្នុង៖** ស្រះ □ ចំនួន..................ក្រឡាផ្ទៃ.....................................................
បែ □ ចំនួន..................ក្រឡាផ្ទៃ.....................................................
ស៊ង □ ចំនួន..................ក្រឡាផ្ទៃ.....................................................
ផ្សេងៗ..........................................................................................

មាននិយាមកា (បំពេញដោយមន្ត្រីជំនាញនៅពេលចុះទៅពិនិត្យទីតាំងជាក់ស្តែង) ..........................................
.............................................................................................................................................
មានទីតាំងស្ថិតនៅភូមិ.........................................................ឃុំ/សង្កាត់..............................................
ក្រុង/ស្រុក/ខណ្ឌ..............................................................រាជធានី/ខេត្ត...........................................។

**២- ប្រភេទវារីវប្បកម្ម៖** វារីសត្វ□ វារីរុក្ខជាតិ□ ពូជក្នុងប្រទេស□ ពូជក្រៅប្រទេស□ ពូជថ្មី□

-.................................................................................ចំនួន.................................... ក្បាល
-.................................................................................ចំនួន.................................... ក្បាល
-.................................................................................ចំនួន.....................................ដើម
-.................................................................................ចំនួន.....................................ដើម

**៣- ឯកសារភ្ជាប់៖**

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)...................................................................... ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ) ...................................................................... ចំនួន១ច្បាប់
- កិច្ចសន្យាធ្វើវារីវប្បកម្ម ...................................................................... ចំនួន១ច្បាប់
- ឯកសារបញ្ជាក់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ឬកិច្ចសន្យាជួល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)...................................................................... ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច)...................................... ចំនួន១ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរឃុំ/សង្កាត់ (ករណីទីតាំងស្នើសុំជាទ្រព្យសម្បត្តិសាធារណៈ)... ចំនួន១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

............................ថ្ងៃទី................ខែ..............ឆ្នាំ២០......

**ហត្ថលេខា/ស្នាមមេដៃ និងឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# ស្តីពី
# ការធ្វើវារីវប្បកម្ម...................

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................អាយុ.........ឆ្នាំ ជនជាតិ..................សញ្ជាតិ........................
អត្តសញ្ញាណប័ណ្ណលេខ........................................មុខរបរបច្ចុប្បន្ន..................................................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.................ផ្លូវលេខ........................ភូមិ.....................................................
ឃុំ/សង្កាត់....................................................ក្រុង/ស្រុក/ខណ្ឌ...................................................
រាជធានី/ខេត្ត...................................................ទូរស័ព្ទលេខ.........................................................។

**ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថា៖**

- មិនចាប់កូនត្រីពីធម្មជាតិមកចិញ្ចឹម ឬថៃបំប៉ន
- ត្រូវកត់ត្រាប្រតិបត្តិការក្នុងសៀវភៅកំណត់ត្រាវារីវប្បកម្មដែលកំណត់ដោយរដ្ឋបាលជលផល
- គោរពតាមបទបញ្ជាបច្ចេកទេសវារីវប្បកម្ម និងគោលការណ៍អនុវត្តន៍វារីវប្បកម្មល្អ និងទទួលយកការណែនាំ និងសេវាបច្ចេកទេសពីរដ្ឋបាលជលផល
- មិនប្រើចំណីកូនត្រីដែលចាប់ពីធម្មជាតិ ឬផលនេសាទបានមកពីការធ្វើនេសាទខុសច្បាប់ ឬឧបករណ៍នេសាទហាមឃាត់
- ករណីសង្ស័យថាប្រភេទវារីវប្បកម្មមានជំងឺ ឬមានជំងឺកំពុងរាតត្បាតត្រូវរាយការណ៍ជាបន្ទាន់ជូនមន្ត្រីជលផលមានសមត្ថកិច្ចដែលនៅជិត ដើម្បីចាត់វិធានការបានទាន់ពេលវេលា
- គោរពតាមយ៉ាងម៉ឺងម៉ាត់នូវបញ្ញត្តិច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថាគោរពឱ្យបានដាច់ខាតតាមបណ្តាចំណុចទាំងអស់ខាងលើ ដើម្បីទុកជាភស្តុតាងខ្ញុំបាទ/នាងខ្ញុំសូមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំចំពោះមុខច្បាប់។

............................ថ្ងៃទី...........ខែ..............ឆ្នាំ២០......

**ហត្ថលេខា ឬស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត**.............................
**ក្រុង ស្រុក ខណ្ឌ**.......................
**ឃុំ/សង្កាត់**...............................
លេខ.....................

## លិខិតបញ្ជាក់ទីតាំង

**(សម្រាប់ការស្នើសុំលិខិតអនុញ្ញាតធ្វើវារីវប្បកម្ម)**

**យើងមេឃុំ/ចៅសង្កាត់**

**សូមបញ្ជាក់ថា**

ឈ្មោះ..................................ភេទ.........ថ្ងៃខែឆ្នាំកំណើត..........................កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ..................................ចុះថ្ងៃទី.........ខែ...........ឆ្នាំ.................ទីលំនៅអចិន្ត្រៃយ៍: ផ្ទះលេខ/ដីឡូត៍លេខ....................................ផ្លូវ....................................ភូមិ.............................................ឃុំ/សង្កាត់...............................ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត...................................។

**មានបំណងធ្វើវារីវប្បកម្ម**

១- នៅក្នុង៖ ស្រះ □ ចំនួន...........................ក្រឡាផ្ទៃ ..............................................
បែ □ ចំនួន...........................ក្រឡាផ្ទៃ ..............................................
ស៊ង □ ចំនួន...........................ក្រឡាផ្ទៃ ..............................................
ផ្សេងៗ.......................................................................................................

២- ប្រភេទវារីវប្បកម្ម៖ វារីសត្វ□ វារីរុក្ខជាតិ□ ពូជក្នុងប្រទេស□ ពូជក្រៅប្រទេស□ ពូជថ្មី□

- ................................................................................. ចំនួន.................................... ក្បាល
- ................................................................................. ចំនួន.................................... ក្បាល
- ................................................................................. ចំនួន......................................ដើម
- ................................................................................. ចំនួន......................................ដើម

មានទីតាំងស្ថិតនៅភូមិ.........................................ឃុំ/សង្កាត់.......................................................
ក្រុង/ស្រុក/ខណ្ឌ.......................................រាជធានី/ខេត្ត.......................................................ពិតប្រាកដមែន។

**លិខិតបញ្ជាក់នេះចេញឱ្យសាមីជន ដើម្បីប្រើប្រាស់តែចំពោះការអាស្រ័យផលក្នុងការធ្វើវារីវប្បកម្មតែប៉ុណ្ណោះ។**

ថ្ងៃ...................ខែ...................ឆ្នាំ....................ព.ស.២៥....

ធ្វើនៅ................ថ្ងៃទី..........ខែ.........ឆ្នាំ.........

**មេឃុំ/ចៅសង្កាត់**

(ហត្ថលេខា និងត្រា)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

LOGO

រាជធានី

ខេត្ត

រូបថត

៤ x ៦

**រដ្ឋបាលរាជធានី ខេត្ត...........**

**លេខ..........................**

## លិខិតអនុញ្ញាតធ្វើវារីវប្បកម្ម..........

**យោង** ៖-ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

-អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយ។

បានអនុញ្ញាតឱ្យលោក-លោកស្រី.........................កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ.......................

ចុះថ្ងៃទី...........ខែ...........ឆ្នាំ...........មានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន...........................................

.................................................................................................................................................

**ធ្វើវារីវប្បកម្ម៖**

**១- នៅក្នុង៖** ស្រះ ☐ ចំនួន........................... ក្រឡាផ្ទៃ ...........................

បែ ☐ ចំនួន........................... ក្រឡាផ្ទៃ ...........................

ស៊ង ☐ ចំនួន........................... ក្រឡាផ្ទៃ ...........................

ផ្សេងៗ.....................................................................................................

**២- ប្រភេទវារីវប្បកម្ម៖** វារីសត្វ ☐ វារីរុក្ខជាតិ ☐ ពូជក្នុងប្រទេស ☐ ពូជក្រៅប្រទេស ☐ ពូជថ្មី ☐

- ........................................ ចំនួន ........................................ ក្បាល
- ........................................ ចំនួន ........................................ ក្បាល
- ........................................ ចំនួន ........................................ ដើម
- ........................................ ចំនួន ........................................ ដើម

មានទីតាំងស្ថិតនៅភូមិ...............................ឃុំ/សង្កាត់...............................................

ក្រុង/ស្រុក/ខណ្ឌ...............................រាជធានី/ខេត្ត...............................ពិតប្រាកដមែន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល១(មួយ)ឆ្នាំ គិតពីថ្ងៃចេញលិខិតអនុញ្ញាតនេះ។

ថ្ងៃ..................ខែ...........ឆ្នាំ..............ព.ស.២៥....

..........................ថ្ងៃទី.........ខែ..............ឆ្នាំ២០.....

**អភិបាល**

ONE WINDOW SERVICE UNIT

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំចុះឈ្មោះចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ
# ស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេស
# សម្រាប់ការលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................ភេទ...........អាយុ..............ឆ្នាំ ជនជាតិ..............សញ្ជាតិ.............. មុខរបរ/តួនាទី.................................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ...............................ផ្លូវ............................... ភូមិ.....................................ឃុំ/សង្កាត់..........................................ក្រុង/ស្រុក/ខណ្ឌ................................... រាជធានី/ខេត្ត.................................លេខទូរស័ព្ទ.........................................។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**.................

**កម្មវត្ថុ** ៖ សំណើសុំចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ស្តីពីបទដ្ឋានគតិយុត្ត និតិវិធី និងវិធានបច្ចេកទេស សម្រាប់ការលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្ម ដែលមុននឹងទទួលបានសិទ្ធិធ្វើអាជីវកម្ម ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គសមត្ថភាពវិជ្ជាជីវៈ ទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដើម្បីបំពេញតាមលក្ខខណ្ឌនេះ ខ្ញុំបាទ/នាងខ្ញុំសូមស្នើសុំអនុញ្ញាតចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ តាមកម្មវិធីសិក្សា កំណត់ដោយបុរេលក្ខខណ្ឌសម្រាប់ទទួលបានលិខិតអនុញ្ញាតស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

**ខ្ញុំសូមសន្យាថា៖**

១. បង់កម្រៃសេវាសម្រាប់ធ្វើដំណើរការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ស្របតាមលិខិតបទដ្ឋានគតិយុត្តកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. គោរពតាមលក្ខខណ្ឌ និងពេលវេលានៃការជូនដំណឹងអំពីការរៀបចំបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។

៣. នៅពេលចូលរួមក្នុងវគ្គ គោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់កម្មវិធីវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។

៤. សហការ និងបង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាព ការងារមន្ត្រីសម្របសម្រួលវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។

៥. ក្រោយពេលបញ្ចប់វគ្គដោយជោគជ័យ ត្រូវរង់ចាំការជូនដំណឹងអំពីការមកទទួលវិញ្ញាបនបត្របញ្ជាក់ឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ដែលកំណត់ដោយមន្ត្រីមានសមត្ថកិច្ច ។

៦. គោរពតាមមនសិការវិជ្ជាជីវៈនៅពេលធ្វើអាជីវកម្មលក់ដុំលក់រាយថ្នាំកសិកម្ម ជីកសិកម្ម និងគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**សូមជូនភ្ជាប់ជាមួយនូវ** ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)..................................................................................................ចំនួន១ច្បាប់
- រូបថត ៤x៦..................................................................................................ចំនួន២សន្លឹក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

..............................ថ្ងៃទី..........ខែ............ឆ្នាំ២០....

**ហត្ថលេខា/ស្នាមមេដៃ និងឈ្មោះ**

(ក្បាលលិខិតរបស់រដ្ឋបាលរាជធានី ខេត្ត)

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ សំណើសុំគ្រូឧទ្ទេសសម្រាប់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្ម។

**យោង** ៖ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា រដ្ឋបាលរាជធានី/ខេត្ត............................ បានទទួលពាក្យស្នើសុំចូលរៀនវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្ម ពីសិក្ខាកាមចំនួន............. នាក់ (ដូចមានក្នុងបញ្ជីឈ្មោះសិក្ខាកាមជូនភ្ជាប់មកជាមួយ) ដែលចំនួននេះគ្រប់គ្រាន់សម្រាប់ដំណើរការវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ។ ដើម្បីឱ្យសិក្ខាកាមមានសមត្ថភាពវិជ្ជាជីវៈគ្រប់គ្រាន់ និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាបុរេលក្ខខណ្ឌសម្រាប់ការទទួលលិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្ម រដ្ឋបាលរាជធានី ខេត្ត.................. សូមគោរពស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាចាត់គ្រូឧទ្ទេសសម្រាប់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់សិក្ខាកាម ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុលោមតាមមាត្រា៨៥ នៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ/នាងខ្ញុំ។

**អភិបាល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

(គំរូវិញ្ញាបនបត្រ)

លេខ.................................កសក.....

| រូបថត<br>៤x៦ ស.ម |
|---|

## វិញ្ញាបនបត្របញ្ជាក់
## ការចូលរួមវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ

**សូមបញ្ជាក់ថា**

លោក/លោកស្រី..............................................អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ......................................មានអាសយដ្ឋានស្ថិតនៅ.................. ..................................................................... បានចូលរួមវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈស្តីពី "**មូលដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសសម្រាប់ការធ្វើអាជីវកម្មថ្នាំកសិកម្ម និងជីកសិកម្ម**" ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី.....ខែ...........ឆ្នាំ........... ដល់ថ្ងៃទី...... ខែ........... ឆ្នាំ............ ដែលបានសហការរៀបចំដោយរដ្ឋបាលរាជធានី ខេត្ត.................................... និងនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វិញ្ញាបនបត្រនេះ ត្រូវបានប្រគល់ជូនសិក្ខាកាមដែលមានសមត្ថភាពឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ សម្រាប់កិច្ចប្រតិបត្តិការល្អក្នុងការធ្វើអាជីវកម្មលក់ដុំលក់រាយថ្នាំកសិកម្ម/និងជីកសិកម្មរបស់ខ្លួន។

ថ្ងៃ.............................. ខែ.................... ឆ្នាំ ........................ព.ស.២៥.....
រាជធានីភ្នំពេញ ថ្ងៃទី....................... ខែ.................... ឆ្នាំ២០....

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

<u>បញ្ជាក់៖</u>

- វិញ្ញាបនបត្រមួយអាចដាក់ពាក្យស្នើសុំប្រកបអាជីវកម្មបានតែមួយកន្លែងប៉ុណ្ណោះ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយ ថ្នាំកសិកម្ម ឬជីកសិកម្ម ឬចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..............................ភេទ...........អាយុ.............ឆ្នាំ ជនជាតិ..............សញ្ជាតិ.............. មុខរបរ/តួនាទី......................................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ..............................ផ្លូវ.............................. ភូមិ..................................ឃុំ/សង្កាត់.........................................ក្រុង/ស្រុក/ខណ្ឌ................................... រាជធានី/ខេត្ត..................................លេខទូរស័ព្ទ.......................................។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត............**

**កម្មវត្ថុ** ៖ សំណើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយ☐ជីកសិកម្ម ☐ថ្នាំកសិកម្ម ☐ចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ មានបំណងសុំលិខិតអនុញ្ញាតលក់ដុំលក់រាយ៖

☐ ជីកសិកម្ម ចំនួន........................តោន (លើសពី ១០០០តោនឡើងទៅ)

☐ ថ្នាំកសិកម្ម ចំនួន.......................តោន (លើសពី ១០តោនឡើងទៅ)

☐ ចម្រុះនូវថ្នាំកសិកម្ម និងជីកសិកម្ម ដែលមាន៖

- ជីកសិកម្មចំនួន.......................តោន (លើសពី ១០០០តោនឡើងទៅ) និង
- ថ្នាំកសិកម្មចំនួន.......................តោន (លើសពី ១០តោនឡើងទៅ)

ដែលមានអាជីវកម្មឈ្មោះ..................................................................................................... មានទីតាំងស្ថិតនៅ ៖ ផ្ទះ/អគារ...............................ផ្លូវ...............................ភូមិ............................... ឃុំ/សង្កាត់.............................ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត...............................។

**សូមជូនភ្ជាប់ជាមួយនូវ** ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន)................................................................................ ចំនួន១ច្បាប់
- សៀវភៅស្នាក់នៅ (ថតចម្លង) ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកស្នើសុំខុសពីអត្តសញ្ញាណប័ណ្ណ).................................................................................ចំនួន១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម ចំពោះអ្នកស្នើសុំជានីតិបុគ្គល(ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ........................................................ ចំនួន១ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ (ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) .....................................................................................................ចំនួន១ច្បាប់
- រូបថត៤x៦ ............................................................................................ ចំនួន២សន្លឹក។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម ឯកឧត្តម/**លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

.........................ថ្ងៃទី..........ខែ...........ឆ្នាំ២០.....

**ហត្ថលេខា/ស្នាមមេដៃ និងឈ្មោះ**

VM

LOGO
រាជធានី
ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
ទំហំ ៤x៦

**មន្ទីរធានាគារធានី/ខេត្ត**..................
លេខ..................................

# លិខិតអនុញ្ញាតលក់ដុំលក់រាយថ្នាំកសិកម្ម

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
-អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-ប្រកាសលេខ១២០ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីនីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
-ប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយ

## សម្រេច

បានអនុញ្ញាតឱ្យលោក-លោកស្រី............................ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ................................ ចុះថ្ងៃទី............ ខែ ............... ឆ្នាំ ...............
អាសយដ្ឋានបច្ចុប្បន្ន .....................................................................................................................
សាខារបស់ក្រុមហ៊ុន .....................................................................................................................
ធ្វើប្រតិបត្តិការលក់ដុំលក់រាយថ្នាំកសិកម្មបរិមាណ..............................................................តោន សម្រាប់ធ្វើការលក់ដុំលក់រាយប្រចាំឆ្នាំ
អាជីវកម្មឈ្មោះ ......................................................................... អាសយដ្ឋានស្ថិតនៅ.........................................................
.....................................................................................................................................................។
លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ លើកលែងតែមានការដកហូត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម នៅមុនកាលបរិច្ឆេទផុតសុពលភាព។
លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មជាធរមាន។

ថ្ងៃ.............................. ខែ.............. ឆ្នាំ..................... ព.ស. ២៥.....
.................................ថ្ងៃទី.......... ខែ.............. ឆ្នាំ២០.....
**អភិបាល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

LOGO
រាជធានី
ខេត្ត

រូបថត
ទំហំ ៤x៦

រដ្ឋបាលរាជធានី/ខេត្ត..........................

លេខ..........................................

# លិខិតអនុញ្ញាតលក់ដុំលក់រាយជីកសិកម្ម

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម

-អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ប្រកាសលេខ១១៩ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម

-ប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយ

## សម្រេច

បានអនុញ្ញាតឱ្យលោក-លោកស្រី.............................. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................................... ចុះថ្ងៃទី............ខែ ............ឆ្នាំ ............

អាសយដ្ឋានបច្ចុប្បន្ន ..........................................................................................................................................

សាខារបស់ក្រុមហ៊ុន ..........................................................................................................................................

ធ្វើប្រតិបត្តិការលក់ដុំលក់រាយជីកសិកម្មបរិមាណ..........................................................................តោន សម្រាប់ធ្វើការលក់ដុំលក់រាយប្រចាំឆ្នាំ

អាជីវកម្មឈ្មោះ ............................................................................................ អាសយដ្ឋានស្ថិតនៅ.........................................

..........................................................................................................................................................។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ លើកលែងតែមានការដកហូត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម នៅមុនកាលបរិច្ឆេទផុតសុពលភាព។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មជាធរមាន។

ថ្ងៃ..............................ខែ..............ឆ្នាំ..................ព.ស.២៥.....

...............................ថ្ងៃទី...........ខែ.............. ឆ្នាំ២០.....

**អភិបាល**

LOGO
រដ្ឋបាលរាជធានី
ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
ទំហំ ៤x៦

**រដ្ឋបាលរាជធានី/ខេត្ត**.....................
លេខ ..............................................

# លិខិតអនុញ្ញាតលក់ដុំលក់រាយចម្រុះថ្នាំកសិកម្ម និងជីកសិកម្ម

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម
-អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-ប្រកាសលេខ១១៩ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
-ប្រកាសលេខ១២០ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីនីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
-ប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយ

## សម្រេច

បានអនុញ្ញាតឱ្យលោក-លោកស្រី.............................. កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ.................................. ចុះថ្ងៃទី............ខែ ..............ឆ្នាំ ............
អាសយដ្ឋានបច្ចុប្បន្ន ........................................................................................................................................
សាខារបស់ក្រុមហ៊ុន ........................................................................................................................................
ធ្វើប្រតិបត្តិការលក់ដុំលក់រាយថ្នាំកសិកម្មបរិមាណ................................ តោន និងជីកសិកម្មបរិមាណ..............................តោន សម្រាប់ធ្វើការលក់ដុំលក់រាយប្រចាំឆ្នាំ
អាជីវកម្មឈ្មោះ ........................................................................ អាសយដ្ឋានស្ថិតនៅ........................................................
..............................................................................................................................................................។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនេះ លើកលែងតែមានការដកហូត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម នៅមុនកាលបរិច្ឆេទផុតសុពលភាព។

លិខិតអនុញ្ញាតនេះ ត្រូវបានប្រគល់ជូនសាមីអ្នកស្នើសុំដើម្បីប្រើប្រាស់ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មជាធរមាន។

ថ្ងៃ.......................ខែ............ឆ្នាំ...................ព.ស. ២៥.....
.................................ថ្ងៃទី........ ខែ............ ឆ្នាំ២០.....

**អភិបាល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលសត្វ (បសុពេទ្យាបាល) សម្រាប់ការធ្វើចរាចរសត្វនៅក្នុងផ្ទៃប្រទេស

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................ភេទ..........អាយុ........ឆ្នាំ ជនជាតិ........សញ្ជាតិ.......... មុខរបរបច្ចុប្បន្ន........................កាន់អត្តសញ្ញាណបណ្ណលេខ...................ចុះថ្ងៃទី...........ខែ........ឆ្នាំ............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ..............ផ្លូវ.......................ភូមិ.......................ឃុំ/សង្កាត់........................... ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត..........................ទូរស័ព្ទលេខ................................។

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត............**

